សប្តាហ៍ទី
45

តង្វាយពីរសេន
របស់ស្ត្រីមេម៉ាយ

ស្ត្រីមេម៉ាយបានថ្វាយប្រាក់កាក់ដ៏តូចចំនួនពីរដល់ព្រះជាម្ចាស់។ ឥស! យើងថ្វាយតង្វាយចេញពីចិត្តដឹងគុណដល់ព្រះជាម្ចាស់ទាំងអស់គ្នា!

រឿងក្នុងព្រះគម្ពីរ

ព្រះយេស៊ូគង់នៅក្នុងព្រះវិហារ ព្រះអង្គទតមើលរបៀបដែលបណ្តាជនថ្វាយតង្វាយ។

អ្នកមានច្រើននាក់បានដាក់ប្រាក់យ៉ាងច្រើន។ ពេលនោះ មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយកប្រាក់ពីរសេនជាចំនួនដ៏តិចតួចបំផុត មកដាក់ក្នុងហឹបតង្វាយនោះដែរ។

ព្រះយេស៊ូហៅពួកសិស្សមក ហើយមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះ បានដាក់ប្រាក់ក្នុងហឹបច្រើនជាងគេទាំងអស់»។

ពីព្រោះគាត់បានយកប្រាក់ដែលគាត់ត្រូវការជាចាំបាច់សម្រាប់ចិញ្ចឹមជីវិតមកដាក់ថ្វាយ។

«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់ ម៉ាកុស ១២:៤៣]

ការតុបតែងស្រោមសំបុត្រតង្វាយរបស់ខ្ញុំ



វត្ថុបំណង

- យល់ពីរឿងរ៉ាវនៃការថ្វាយតង្វាយរបស់ស្ត្រីមេម៉ាយ
- បង្ហាញពីការដឹងគុណតាមរយៈការប្រើប្រាស់សម្ភារៈសិល្បៈផ្សេងៗ
- ស្វែងយល់ពីគំរូរបស់ស្ត្រីមេម៉ាយដែលបានថ្វាយអ្វីៗទាំងអស់ដែលនាងមាន
- ជាត់ពណ៌ និងតុបតែងស្រោមសំបុត្រ ដើម្បីបង្ហាញពីការដឹងគុណ។

សម្ភារៈ

- ស្រោមសំបុត្រតង្វាយ
- ខ្មៅដៃពណ៌ ហ្វឺតពណ៌ កូលំរទៀន
- ស្ទីគ័ររូបផ្សេងៗ (បើមាន)

របៀបធ្វើសកម្មភាព

1. យកស្រោមសំបុត្រតង្វាយមួយ។
2. សរសេរឈ្មោះរបស់អ្នកនៅលើស្រោមសំបុត្រនោះ។
3. តុបតែងនៅផ្នែកខាងមុខឱ្យបានស្រស់ស្អាត។
4. សរសេរ ឬគូររូបបង្ហាញពីចិត្តដឹងគុណរបស់អ្នក។
5. បង្ហាញវាទៅមិត្តភក្តិ ហើយចែករំលែកប្រាប់ពួកគេ!



ការពង្រីកសកម្មភាព

- តុបតែងស្រោមសំបុត្រតង្វាយ ដោយប្រើពណ៌ និងក្បាច់រចនាប្លែកៗគ្នា។
- បង្ហាញពីទឹកចិត្តដែលអ្នកចង់ថ្វាយដល់ព្រះជាម្ចាស់។
- លើកទឹកចិត្តមិត្តភក្តិឱ្យថ្វាយតង្វាយរបស់ពួកគេដោយចិត្តដឹងគុណ។
- ប្រមូលស្រោមសំបុត្រដែលធ្វើរួច ហើយយកទៅថ្វាយរួមគ្នានៅព្រះវិហារ។

Tip សម្រាប់គ្រូ

- និយាយរម្លឹកប្រាប់កុមារអំពីអត្ថន័យនៃការថ្វាយដោយចិត្តទូលាយ។
- ការផ្តល់សម្ភារៈឱ្យបានច្រើនប្រភេទ នឹងជួយបង្កើតគំនិតច្នៃប្រឌិតកាន់តែច្រើនដល់កុមារ។
- សរសើរពីទឹកចិត្តរបស់កុមារដែលចង់ថ្វាយតង្វាយដោយការដឹងគុណ។
- លើកទឹកចិត្តឱ្យកុមារទទួលបានអារម្មណ៍អំណរ ក្នុងការថ្វាយដោយមានចិត្តដឹងគុណ។